# កំណាព្យ

## ដូរដូច

បទព្រហ្មគីតិ

ស្លឹកឈើដូរពណ៌ស្រស់ នឹកស្រណោះផ្កាកុលាប
ស្រទាប់ធ្លាក់ក្លិនសាប ខ្យល់បង្រ្កាបឱ្យឃ្លាតទង។
លាមែកទុករលីក ពេលរលីមជ្រុះពីវន[1]
ព្រោះបុប្ផាស្រពោន ស្រទាប់ទ្រោមនឹងវាយោ។

ឃើញអូនដូរផាហ៊ុម ទាញផួយរុំកាយត្រជាក់
តែពៅបានបញ្ជាក់ មានសច្ចៈក្នុងចិត្តស្រី។
ថាបងជាស្នេហ៍ពិត ជានិមិត្ត[2]នៃរស្មី
មិនយករដូវថ្មី ដូរសួស្តីតាមធម្មជាតិ។

ខែកត្តិកសីតកាល[3] ពេលរំគាលកំដៅដែរ
តែចិត្តនៅតែថែ សម្ភព[4]ស្នេហ៍ជាគូគ្រង
មិនដូចផ្កាកុលាប មានសម្ភាពន៍[5]ឆោមពីទង
តែខ្លួនខ្វះគំរោង គ្មានទំនងឈ្នះរដូវ។

[1] វន ឬ វ័ន : ន. ទីអាស្រ័យ។ ប្រើផ្សំជាមួយនឹងសព្ទដទៃ : វនទេវតា, បុប្ផាវន។
[2] និមិត្ត : ន. លក្ខណៈ, គោល, ចារឹក។
[3] សីត : ត្រជាក់ : សីតកាល : រដូវរងា។
[4] សម្ភព : ន. ការកើតដោយល្អ។
[5] សម្ភាពន៍ : ន. សេចក្ដីសរសើរ។